# MentalHigh

ព្រឹត្តិបត្រព័ត៌មាន ភាគ ២

## កិច្ចប្រជុំដៃគូផ្ទាល់មុខ នៅទីក្រុង Valencia

ចាប់ពីថ្ងៃទី 27 ដល់ថ្ងៃទី 31 ខែឧសភា ឆ្នាំ 2024 កិច្ចប្រជុំ MentalHigh Consortium ត្រូវបានធ្វើឡើងនៅសាកលវិទ្យាល័យFundació Universitat Empresa (ADEIT) នៅកណ្តាលទីក្រុង Valencia ប្រទេសអេស្ប៉ាញ។ កិច្ចប្រជុំនេះមានការចូលរួមពីតំណាងនៃសាកលវិទ្យាល័យទាំងអស់ដែលជាដៃគូនៃគម្រោង MentalHigh ដូចជា HAW, VNU, TUEBA, VUTED, NIE, RUPP, TUAF, VNU USSH, TURKU AMK និង UJI ។

ក្នុងឱកាសនៃកិច្ចប្រជុំនេះ តំណាងពីដៃគូនីមួយៗក្នុងគម្រោងបានជួបមុខគ្នាដោយផ្ទាល់ ហើយបានផ្លាស់ប្តូរអំណោយ ក៏ដូចជាចែករំលែកនូវពីបទពិសោធន៍ល្អៗអំពីគម្រោង។ ការធ្វើបទបង្ហាញអំពីវឌ្ឍនភាពរបស់សកម្មភាពការងារគម្រោងបានធ្វើឡើង ក្រោមប្រធានបទដូចជាការបោះពុម្ពផ្សាយបែបវិទ្យាសាស្ត្រនាពេលអនាគត ការសម្អាសផ្តោតលើការពិភាក្សាក្រុម និងការវិភាគ និងការអភិវឌ្ឍន៍កម្មវិធីអន្តរាគមន៍ឌីជីថល 'MoodCare និង Shinig mind app។

ជាងនេះទៅទៀតដៃគូក៏បានរៀបចំផែនកា



*MentalHigh Consortium នៅ Valencia, ខែមិថុនា 2024*

ព្រឹត្តិការណ៍ស្តីពីសុខភាពផ្លូវចិត្ត សិក្ខាសាលាពង្រឹងសមត្ថភាព ការផ្សព្វផ្សាយពីគម្រោងលើគេហទំព័រ និង logo របស់គម្រោងផងដែរ។

កិច្ចប្រជុំបានបញ្ចប់ទៅជាមួយនឹងផ្លែផ្កាហើយដែល បានរួមចំណែកដល់ដំណើរវិវឌ្ឍន៍របស់គម្រោង។ លើសពីនេះ អ្នកតំណាងអាចរីករាយនឹងការទស្សនារប្បធម៌នូវទាំងទីក្រុង Valencia។ អង្គប្រជុំបានសម្រេច នៅខែមករាឆ្នាំ 2025 កិច្ចប្រជុំដៃគូបន្ទាប់គឺនឹងធ្វើឡើងនៅប្រទេសកម្ពុជា។

**MentalHigh timeline ក្នុងរយៈពេល 6 ខែចុងក្រោយនេះ។**

MentalHigh
Building Mental Health Capacity at Higher Education Institutes in Southeast Asia

Co-funded by the Erasmus + Programme of the European Union

# MentalHigh

ព្រឹត្តិបត្រព័ត៌មាន ភាគ ២



# MentalHigh



## ក្រុមប្រឹក្សានិស្សិត ត្រូវបានបង្កើតឡើង

ថ្ងៃទី 8 ខែមករា ឆ្នាំ 2024 សមាជិកជានិស្សិត ចំនួន 14 នាក់ត្រូវបានតែងតាំងជាក្រុមប្រឹក្សានិស្សិតក្នុងគម្រោងMentalHigh ក្នុងអំឡុងពេលកិច្ចប្រជុំដែលដឹកនាំដោយលោកសាស្ត្រាចារ្យបណ្ឌិត Gunter Groen មកពីសាកលវិទ្យាល័យ Hamburg University of Applied Sciences ប្រទេសអាល្លឺម៉ង់ (HAW) ដែលជាអ្នកសម្របសម្រួលគម្រោង។




សមាជិកក្រុមប្រឹក្សានិស្សិតដែលត្រូវបានតែងតាំងថ្មីនីមួយៗបានសន្យាថានឹងតំណាងឱ្យនិស្សិតនៃសាកលវិទ្យាល័យដៃគូ MentalHigh រៀងៗខ្លួន ដោយធានាថាតម្រូវការ និងគំនិតរបស់ពួកគេត្រូវបានឆ្លុះបញ្ចាំងយ៉ាងល្អនៅក្នុងខ្លឹមសាររបស់គម្រោង MentalHigh។ ក្នុងអំឡុងពេលកិច្ចប្រជុំដៃគូដោយផ្ទាល់នៅទីក្រុង Valencia ប្រទេសអេស្ប៉ាញ អ្នកតំណាងមកពីស្ថាប័ននីមួយៗបានទទួល វិញ្ញាបនបត្រនៃការតែងតាំង និងបញ្ជូនបន្តដល់សមាជិកក្រុមប្រឹក្សានិស្សិត។ ការទទួលស្គាល់ជាផ្លូវការនេះបង្ហាញពីសារៈសំខាន់នៃតួនាទីរបស់និស្សិតក្នុងទិសដៅដឹកនាំ និងផលជះរបស់គម្រោង Mental High ។ ក្នុងអំឡុងពេលនៃការចាត់តាំងនេះក្រុមប្រឹក្សានិស្សិត MentalHigh

លោកសាស្ត្រាចារ្យ. Phan Chanpeou
បាទទទួលវិញ្ញាបនបត្រតែងតាំងពីលោកសាស្ត្រាចារ្យបណ្ឌិត Gunter Groen
ក្នុងនាមសមាជិកក្រុមប្រឹក្សានិស្សិត RUPP

បានចូលរួមយ៉ាងសកម្មក្នុងកិច្ចការងារនៃកញ្ចប់ការងារទី៣ WP3 ទាក់ទងនឹងការបន្សាំទៅនឹងវប្បធម៌ (cultural Adaptation)។ ការចូលរួមចំណែកដ៏សំខាន់ដំបូងមួយទៀតរបស់ពួកគេគឺការពិនិត្យមើល មេរៀន (Module)"ការណែនាំ និងស្វាគមន៍" នៃគម្រោងស្នាមញញឹមគឺភាពសប្បាយ (Smiling is fun project)។ ដូចគ្នានេះផងដែរ សមាជិកក្រុមប្រឹក្សានិស្សិតបានបោះឆ្នោតដើម្បីប្តូរឈ្មោះវគ្គសិក្សាអន្តរាគមន៍ឌីជីថលរបស់ MentalHigh ទៅជា "MoodCare"ដែលជាចំណងជើងស្របនឹងគោលដៅ និងគោលបំណងរបស់គម្រោង។ ក្រុមការងារ MentalHigh សូមថ្លែងអំណរគុណចំពោះ ក្រុមប្រឹក្សានិស្សិតសម្រាប់ការងាររបស់ពួកគេ ហើយរំពឹងថាការរួមចំណែករបស់ពួកគេនឹងជះឥទ្ធិពលជាវិជ្ជមានដល់បរិយាកាសសិក្សានៅប្រទេសវៀតណាម និងកម្ពុជា។

## **កញ្ចប់ការងារទី ២ (WP2 Mapping the landscape) បានបញ្ចប់**

ការកំណត់Landscapeក្នុងការសិក្សាស្រាវជ្រាវត្រូវបានបញ្ចប់ដោយជោគជ័យតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ដៃគូរបស់គម្រោង។ កញ្ចប់ការងារនេះត្រូវបានដឹកនាំដោយសាកលវិទ្យាល័យវិទ្យាសាស្ត្រអនុវត្ត(Turku UAS) ជាមួយនឹងការគាំទ្រពីដៃគូរបស់ខ្លួន។ គោលដៅចម្បងរបស់ WP2 រួមមានការវាយតម្លៃតម្រូវការសុខភាពផ្លូវចិត្តនៅសាកលវិទ្យាល័យដៃគូ ការកំណត់អត្តសញ្ញាណ

# MentalHigh



ការពិពណ៌នាអំពីធនធានសុខភាពផ្លូវចិត្តដែលមានស្រាប់ និងធ្វើការសម្ភាសន៍ដោយផ្តោតលើក្រុមពិភាក្សា ជាមួយបុគ្គលិក គណៈគ្រប់គ្រង និស្សិត និងភាគីពាក់ព័ន្ធពីខាងក្រៅ ដើម្បីប្រមូលទិន្នន័យដែលពាក់ព័ន្ធ។ ការវិភាគទិន្នន័យក្នុងកញ្ចប់ការងារនេះមានគោលបំណងដើម្បីទទួលបានការយល់ដឹងអំពីចំណេះដឹង អាកប្បកិរិយា និងការមាក់ងាយទាក់ទងនឹងសុខភាពផ្លូវចិត្ត ។ ការសម្ភាសន៍ផ្តោតលើក្រុមពិភាក្សាគឺជាវិធីសាស្រ្តជាកណ្តាលមួយដែលត្រូវបានប្រើដើម្បីប្រមូលទស្សនៈដ៏មានតម្លៃលើការលើកកម្ពស់សុខភាពផ្លូវចិត្តនៅក្នុងថ្នាក់ឧត្តមសិក្សា។ ការយល់ដឹងទាំងនេះនឹងជួយរៀបចំជាគំនិតផ្តួចផ្តើម និងកិច្ចអន្តរាគមន៍នាពេលអនាគត។

# MentalHigh





**ថ្ងៃបណ្តុះបណ្តាល WP2 នៅកម្ពុជា ខែមករា ឆ្នាំ 2024**

ដំណាក់កាលគម្រោង និងចំណុចសំខាន់នៃកញ្ចប់ការងារទី២ WP2 ពាក់ព័ន្ធនឹងដំណាក់កាលសំខាន់ៗជាច្រើន។ ការគ្រប់គ្រងទិន្នន័យរួមបញ្ចូលការបង្កើតផែនការដ៏ទូលំទូលាយមួយដើម្បីដោះស្រាយ ផ្ទេរ និងគ្រប់គ្រងទិន្នន័យប្រកបដោយក្រមសីលធម៌។ វិធីសាស្ត្រក្រុមគោលដៅពាក់ព័ន្ធនឹងការបង្កើតពិធីការបញ្ជីត្រួតពិនិត្យ និងសំណួរសម្រាប់ការសម្ភាសន៍ផ្តោតលើក្រុមពិភាក្សាប្រកបដោយប្រសិទ្ធភាព ការដោះស្រាយបញ្ហាប្រឈម និងការស្នើរសុំដំណោះស្រាយ។ ការវិភាគខ្លឹមសារត្រូវបានធ្វើឡើងតាមរយៈការវិភាគតាមប្រធានបទ រួមទាំងការបកប្រែចាំបាច់ដើម្បីពង្រឹងការយល់ដឹង។

ព្រឹត្តិការណ៍សំខាន់ៗរួមមានការបង្កើតក្រុមប្រឹក្សានិស្សិតនៅចុងរដូវស្លឹកឈើជ្រុះឆ្នាំ 2023 ទទួលបានការយល់ព្រមពីក្រុមប្រឹក្សាក្រមសីលធម៌នៅខែធ្នូ ឆ្នាំ 2023 និងការបញ្ចប់ការសម្ភាសន៍ជាក្រុមទាំងអស់នៅនិទាឃរដូវឆ្នាំ 2024 ។ សាកលវិទ្យាល័យ Turku UAS បានដឹកនាំវគ្គបណ្តុះបណ្តាលផ្សេងៗលើការប្រមូលទិន្នន័យ ការវិភាគ និងការអភិវឌ្ឍន៍ប្រធានគោលក្នុងការវិភាគខ្លឹមសារ ហើយនិងមានការពិគ្រោះយោបល់ជាបន្តបន្ទាប់ក្នុងរយៈពេលនៃការអនុវត្តកញ្ចប់ការងារមួយនេះ។

ជាលទ្ធផលនៃ WP2 យើងទទួលបានព័ត៌មានដ៏មានតម្លៃអំពីតម្រូវការដែលទាក់ទងនឹងការជួយដល់ចំណេះដឹងពីសុខភាពផ្លូវចិត្ត ជាពិសេសការគូសបញ្ជាក់អំពីសារៈសំខាន់នៃការគិតទាក់ទងនឹងសុខភាពផ្លូវចិត្ត និងកត្តាវប្បធម៌ចំពោះសុខុមាលភាពរបស់យើង។ សូមរង់ចាំតាមដានព័ត៌មានថ្មីៗបន្ថែមទៀត នៅពេលដែលយើងបន្តធ្វើឱ្យមានវឌ្ឍនភាពក្នុងការពង្រឹងការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត និងការអប់រំនៅសាកលវិទ្យាល័យដៃគូរបស់យើង។

## ការរីកចម្រើននៃកញ្ចប់ការងារទី៣ទាក់ទងនឹងនឹងការអភិវឌ្ឍន៍ខ្លឹមសារក្នុងវគ្គសិក្សាអនឡាញ MoodCare

ដៃគូដឹកនាំកញ្ចប់ការងារទី៣ នេះគឺ Universitat Jaume I, Spain នៃគម្រោង MentalHigh ដែលបាននឹងកំពុងធ្វើការលើការអភិវឌ្ឍន៍ខ្លឹមសារ ការបកប្រែ និងការបន្សាំតាមវប្បធម៌នៃកម្មវិធីលើកកម្ពស់សុខភាពផ្លូវចិត្តតាមអ៊ីនធឺណេត "MoodCare"។ Moodcare គឺជាអន្តរាគមន៍ផ្លូវចិត្តផ្អែកលើភស្តុតាង ផ្តោតលើបច្ចេកទេសពុទ្ធិអាកប្បកិរិយា ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់រៀន និងអនុវត្តវិធីសម្របខ្លួនដើម្បីទប់ទល់នឹងភាពតានតឹងចិត្ត និងបញ្ហាប្រចាំថ្ងៃ។ វាក៏រួមបញ្ចូលផងដែរនូវយុទ្ធសាស្រ្តផ្លូវចិត្តផ្សេងទៀតដើម្បីបង្កើនអារម្មណ៍វិជ្ជមាន។ កម្មវិធីជួយខ្លួនឯងលើប្រព័ន្ធអ៊ីនធឺណេត បូករួមនឹងការបញ្ចូលគ្នានៃប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗទៀត រួមមានទាំងអស់ 8 មេរៀន ដែលតម្រង់ទិសដើម្បីឱ្យនិស្សិតរៀន និងអនុវត្តវិធីសាស្រ្តបែបចិត្តសាស្រ្តផ្សេងៗគ្នាក្នុងការដោះស្រាយបញ្ហា។ កម្មវិធីនេះត្រូវបានបង្កើតឡើងដោយក្រុម Labpsitec មកពីសាកលវិទ្យា Jaume I ហើយត្រូវបានទទួលស្គាល់អាចជឿជាក់បាន និងធ្លាប់ប្រើប្រាស់ជាមួយក្រុមគោលដៅផ្សេងទៀតជាច្រើនរួចមកហើយ។ ចាប់ពីខែវិច្ឆិការឆ្នាំ២០២៣ ដល់ខែ ឧសភា ឆ្នាំ២០២៤ គម្រោង MentaHigh បានអនុវត្តក្រុមពិភាក្សា លើការបន្សាំនឹងវប្បធម៌នៃខ្លឹមសារមេរៀនក្នុងកម្មវិធី Moodcare។ ដោយមានការសម្របសម្រួលពី Universitat Jaume I. តំណាងពីដៃគូនីមួយៗ បានពិនិត្យមេរៀនទាំងអស់នៃកម្មវិធី ដើម្បីកែសម្រួលសម្ភារៈ និងសារអន្តរាគមន៍ទៅនឹងលក្ខណៈដែលអាចសង្កេតបានស្របទៅនឹងក្រុមគោលដៅ និងដើម្បីបញ្ចូលទស្សនាទានវប្បធម៌ សង្គម ប្រវត្តិសាស្រ្ត បរិស្ថាន និងផ្លូវចិត្តដែលទាក់ទងនឹងនិស្សិតនៅក្នុងប្រទេសវៀតណាមនិងកម្ពុជា។




វីដេអូកំនូរជីវចលដំបូងនៃ MentalHigh MoodCare

ក្នុងប៉ុន្មានខែបន្ទាប់ ក្រុមប្រឹក្សានិស្សិតនៃគម្រោង Mental High នឹងពិនិត្យមើលកំណែចុងក្រោយនៃមេរៀន ដើម្បីមើលថាតើខ្លឹមសារគ្រប់គ្រាន់ហើយឬនៅ។ មេរៀននឹងត្រូវបានបកប្រែជាភាសាខ្មែរ និងវៀតណាម ហើយកម្មវិធី "MoodCare" នឹងអាចដាក់ឱ្យប្រើប្រាស់សម្រាប់ និស្សិតវៀតណាម និងកម្ពុជានៅចុងឆ្នាំ 2024។

# MentalHigh



## ដំណើរទស្សនកិច្ចរបស់សហភាពអឺរ៉ុបនៅកម្ពុជា

នៅថ្ងៃទី 6 ខែមិថុនា ឆ្នាំ 2024 លោក Darren J. McDermott អ្នកវាយតម្លៃខាងក្រៅនៃទីភ្នាក់ងារប្រតិបត្តិការអប់រំ និងវប្បធម៌អឺរ៉ុប (EACEA) បានមកទស្សនកិច្ច និងពិភាក្សាជាមួយដៃគូនៃគម្រោង MentalHigh នៅកម្ពុជា គឺសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) និងវិទ្យាស្ថានជាតិអប់រំកម្ពុជា (NIE) ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្ត និរន្តរភាពនៃគម្រោង ក៏ដូចជាការផ្សព្វផ្សាយ និងការទាញយកលទ្ធផល ដើម្បីស្វែងរកភស្តុតាង និងការអនុវត្តល្អលើផលជះនៃ MentalHigh ។



លោក Darren McDermott នៅវិទ្យាស្ថានជាតិអប់រំកម្ពុជា (NIE) ខែមិថុនា ឆ្នាំ 2024

តំណាង RUPP និង NIE ប្រចាំប្រទេសកម្ពុជាបានចូលរួមក្នុងដំណើរទស្សនកិច្ចត្រួតពិនិត្យ រួមជាមួយនឹងក្រុមគម្រោង Mental High និងអ្នកស្ម័គ្រចិត្តមកពីក្រុម RUPP និង NIE ។ នៅក្នុងកិច្ចប្រជុំនេះ ក្រុមការងារ Mentalhigh កម្ពុជា បានធ្វើបទបង្ហាញអំពីគម្រោង MentalHigh ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃ MentalHigh ក្នុងការកសាងសមត្ថភាពរបស់ស្ថាប័ននៅថ្នាក់ឧត្តមសិក្សាក្នុងប្រទេសវៀតណាម និងកម្ពុជា ក៏ដូចជាការលើកឡើងពីការទទួលខុសត្រូវដែល RUPP និង NIE បានអនុវត្ត និងចូលរួម។
លោក McDermott ក៏បានជួបជាមួយសមាជិកក្រុមប្រឹក្សានិស្សិត MentalHigh ហើយបានពិភាក្សាថាតើគម្រោង MentalHigh



បំពេញតម្រូវការរបស់ពួកគេនៅក្នុងបរិយាកាសសិក្សារបស់ពួកគេដែរឬទេ។
នៅចុងបញ្ចប់នៃកិច្ចប្រជុំ លោក McDermott បានផ្តល់មតិជាវិជ្ជមាន និងមតិយោបល់លើដំណើរការគម្រោង។ លោកក៏បានកោតសរសើរចំពោះការគាំទ្រ និងការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ពីគណៈគ្រប់គ្រង។
ដំណើរទស្សនកិច្ចបានបញ្ចប់ក្នុងបរិយាកាសសុទិដ្ឋិនិយម និងគាំទ្រ។

លោក Darren McDermott ជាមួយដៃគូ MentalHigh នៃ សាកលវិទ្យាភូមិន្ទភ្នំពេញ ខែ មិថុនា ឆ្នាំ២០២៤

# MentalHigh

ព្រឹត្តិបត្រព័ត៌មាន ភាគ ២

ដៃគូគម្រោង

- សាកលវិទ្យាល័យHamburg នៃវិទ្យាសាស្ត្រអនុវត្ត (អ្នកសម្របសម្រួលគម្រោង)
- សាកលវិទ្យាល័យអប់រំ VNU ប្រទេសវៀតណាម
- សាកលវិទ្យាល័យ Turku នៃវិទ្យាសាស្ត្រអនុវត្ត ប្រទេសហ្វាំងឡង់
- សាកលវិទ្យាល័យ Jaume I ប្រទេសអេស្ប៉ាញ
- សាកលវិទ្យាល័យ វិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ VNUHCM ប្រទេសវៀតណាម
- សាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ថៃ ង្វៀន ប្រទេសវៀតណាម
- សាកលវិទ្យាល័យ Thai Nguyen ផ្នែកសេដ្ឋកិច្ច និងគ្រប់គ្រងពាណិជ្ជកម្មប្រទេសវៀតណាម
- សាកលវិទ្យាល័យ Vinh University of Technology Education ប្រទេសវៀតណាម
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ប្រទេសកម្ពុជា
- វិទ្យាស្ថានជាតិអប់រំកម្ពុជា

HAW HAMBURG

TURKU AMK
TURKU UNIVERSITY OF APPLIED SCIENCES

UNIVERSITAT JAUME I

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

**ព័ត៌មានលម្អិតទំនាក់ទំនង**

សម្រាប់ព័ត៌មានបន្ថែម ឬការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង: https://mentalhigh.net/